# ពរជ័យមកពីការអធិស្ឋានជាគ្រួសារ ការសិក្សាព្រះគម្ពីរជាគ្រួសារ និងរាត្រីជួបជុំក្រុមគ្រួសារ

នៅពេលអ្នកអានការបង្រៀនខាងក្រោមនេះមកពីថ្នាក់ដឹកនាំសាសនាចក្រ នោះសូមគូសបន្ទាត់ពីក្រោមពរជ័យ ដែលមកពីការអធិស្ឋានជាគ្រួសារប្រចាំថ្ងៃ និងការសិក្សាព្រះគម្ពីរជាគ្រួសារប្រចាំថ្ងៃ និងរាត្រីជួបជុំក្រុមគ្រួសាររាល់សប្តាហ៍ ។



អែលឌើរ រីឆាត ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀន ៖

« ឪពុកម្ដាយ ជួយការពារដល់កូនចៅរបស់អ្នក ដោយបំពាក់ដល់ពួកគេនូវអានុភាពនៃការអធិស្ឋានជាគ្រួសារទាំងព្រឹក និងយប់ ។ . . . សូមការពារកូនចៅរបស់អ្នកកុំឲ្យរងឥទ្ធិពលរបស់លោកិយរាល់ថ្ងៃនេះ ដោយការពង្រឹងពួកគេជាមួយនឹងពរជ័យដ៏មានអំណាច ដែលជាលទ្ធផលមកពីការអធិស្ឋានជាគ្រួសារ ។ ការអធិស្ឋានជាគ្រួសារ គួរតែជាអាទិភាពដ៏មិនអាចដដែកតវ៉ាបាននៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ។

«. . . សូមធ្វើឲ្យ [ ព្រះគម្ពីរ ] ជាផ្នែកដ៏ចម្បងនៃជីវិតរាល់ថ្ងៃនេះ ។ ប្រសិនបើអ្នកចង់ឲ្យកូនៗរបស់អ្នកស្គាល់ យល់ និងធ្វើសកម្មភាពតាមការបំផុសគំនិតនៃព្រះវិញ្ញាណ នោះអ្នកត្រូវតែសិក្សាព្រះគម្ពីរជាមួយនឹងពួកគេ ។ . . . តាមរយៈការសិក្សាព្រះគម្ពីរដោយខ្ជាប់ខ្ជួនប្រចាំថ្ងៃ នោះអ្នកនឹងរកឃើញនូវសេចក្ដីសុខសាន្ត ក្នុងចំណោមចលាចលជុំវិញអ្នក និងមាននូវភាពរឹងមាំដើម្បីប្រឆាំងនឹងការល្បួងទាំងឡាយ ។ អ្នកនឹងអភិវឌ្ឍនូវសេចក្ដីជំនឿដ៏រឹងមាំមួយ នៅក្នុងព្រះគុណនៃព្រះ ហើយដឹងថា តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះមនុស្សទាំងអស់នឹងត្រូវធ្វើឲ្យជាត្រឹមត្រូវ ស្របតាមពេលវេលារបស់ព្រះ » ( “Make the Exercise of Faith Your First Priority,” *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ៩៣–៩៤ ) ។



ស៊ិស្ទើរ លីនដា អេស រីវេស នៃគណៈប្រធានសមាគមសង្គ្រោះទូទៅ បានបង្រៀន ៖

« ខ្ញុំត្រូវតែធ្វើទីបន្ទាល់អំពី ពរជ័យនៃការសិក្សាព្រះគម្ពីរ និងការអធិស្ឋានប្រចាំថ្ងៃ និងរាត្រីជួបជុំក្រុមគ្រួសារប្រចាំសប្តាហ៍ ។ ទាំងនេះ គឺជាការអនុវត្តដ៏ចាំបាច់មួយ ដែលជួយកុំឲ្យមានភាពតានតឹង ផ្ដល់ការដឹកនាំដល់ជីវិតរបស់យើង និង បន្ថែមនូវការការពារដល់គេហដ្ឋានរបស់យើង » ( “Protection from Pornography—a Christ-Focused Home,”*Ensign* ឬ *Liahona* ខែ ឧសភាឆ្នាំ ២០១៤ ទំព័រ ១៦–១៧ ) ។



ប្រធាន ថូម៉ាស អេស ម៉នសុន បានប្រកាសថា

« ការអធិស្ឋានជាក្រុមគ្រួសារ គឺជាការធ្វើឲ្យញញើតនឹងធ្វើបាបយ៉ាងខ្លាំងក្លាបំផុត ហើយហេតុដូច្នេះ វាជាអ្នកផ្ដល់ប្រយោជន៍ដ៏ខ្លាំងបំផុតនៃសេចក្ដីអំណរ និងសុភមង្គល » ( “Hallmarks of a Happy Home,”*Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៨ ទំព័រ ៦៩ ) ។

សូមពិចារណាទៅលើសំណួរខាងក្រោមនេះ ៖

- តើពរជ័យទាំងនេះណាខ្លះ ដែលអ្នកបានទទួលនៅក្នុងគ្រួសាររបស់អ្នក ឬបានឃើញនៅក្នុងគ្រួសាររបស់អ្នកដទៃទៀត ?
- តើអ្នកអាចធ្វើអ្វីខ្លះនាពេលនេះ ដើម្បីទទួលបានពរជ័យទាំងនេះកាន់តែពេញលេញជាងនេះទៅទៀត ?

© ២០១៥ ដោយ Intellectual Reserve, Inc. រក្សាសិទ្ធិគ្រប់យ៉ាង ។

សាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ | ថ្នាក់ទិញ្ញាស្ថានសាសនា